ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខៈ ២៦៣ ប្រ.ក ប.ស្ក

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «បារាយណ៍ខាំកីត» នៃដែនជម្រកសត្វព្រៃ «ឆែប» ស្ថិតនៅភូមិខាំកីត ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ឆែប»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «**បារាយណ៍ខាំកីត**» នៃដែនជម្រកសត្វព្រៃ «ឆែប» ស្ថិតនៅភូមិខាំកីត ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ។

**ប្រការ២.**_

សហគមន៍តំបន់ការពារធម្មជាតិ **«បារាយណ៍ខាំកឹត»** នៃដែនជម្រកសត្វព្រៃ «ឆែប» មានផ្ទៃដីសរុបទំហំ **១១០៨ ហិកតា** (មួយពាន់មួយរយប្រាំបីហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 569420 | 1556220 | 8 | 564221 | 1555100 |
| 2 | 567833 | 1556140 | 9 | 563877 | 1552100 |
| 3 | 567753 | 1555980 | 10 | 564207 | 1551500 |
| 4 | 567595 | 1555830 | 11 | 564889 | 1552480 |
| 5 | 567118 | 1555730 | 12 | 568150 | 1555010 |
| 6 | 564723 | 1555760 | 13 | 569458 | 1555110 |
| 7 | 564606 | 1555450 | | | |

**ប្រការ៣.**_

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«បារាយណ៍ខាំកឹត»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.**_

សហគមន៍តំបន់ការពារធម្មជាតិ **«បារាយណ៍ខាំកឹត»** នៃដែនជម្រកសត្វព្រៃ «ឆែប» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«បារាយណ៍ខាំកឹត»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«បារាយណ៍ខាំកឹត»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ចន្ទ ៥ កើត ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិបារាយណ៍ខាំកឹត ក្នុងភូមិសាស្ត្រដែនជម្រកសត្វព្រៃឆែប
# ភូមិខាំកឹត ឃុំកំពង់ស្រឡៅមួយ ស្រុកឆែប ខេត្តព្រះវិហារ ទំហំ ១១០៨ ហិកតា




សញ្ញាសម្គាល់

- ចំនុចព្រំសហគមន៍
- ទីតាំងភូមិ
- ស្ទឹង
- ផ្លូវ
- ខ្សែរយៈកំពស់
- ព្រំប្រទល់សហគមន៍
- ព្រំប្រទល់តំបន់ការពារ




ចំនុចនិយាមកាព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ខាំកឹត

| Id | X | Y |
|---|---|---|
| 1 | 569420 | 1556220 |
| 2 | 567833 | 1556140 |
| 3 | 567753 | 1555980 |
| 4 | 567595 | 1555830 |
| 5 | 567118 | 1555730 |
| 6 | 564723 | 1555760 |
| 7 | 564606 | 1555450 |
| 8 | 564221 | 1555100 |
| 9 | 563877 | 1552100 |
| 10 | 564207 | 1551500 |
| 11 | 564889 | 1552480 |
| 12 | 568150 | 1555010 |
| 13 | 569458 | 1555110 |

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

រៀបចំដោយ :

នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

មាត្រដ្ឋាន ១ : ៥០ 000

0 1 2 km